ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ០១. បប.

# បទបញ្ជា
## ស្តីពី
## វិធានការបញ្ឈប់ការបិទខ្ទប់ការតភ្ជាប់បណ្តាញសេវាទូរស័ព្ទគ្នា ទៅវិញទៅមករវាងប្រតិបត្តិករទូរស័ព្ទមួយទៅប្រតិបត្តិករទូរស័ព្ទមួយទៀត

តាមរយៈការអនុវត្តគោលនយោបាយបើកទូលាយរបស់រាជរដ្ឋាភិបាល នៅបណ្តាឆ្នាំចុងក្រោយនេះវិស័យទូរគមនាគមន៍បានដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ជាពិសេសមានក្រុមហ៊ុនឯកជនជាច្រើនបានចូលមកវិនិយោគលើវិស័យទូរគមនាគមន៍នៅកម្ពុជា ។

ស្របពេលគ្នានឹងកំណើននៃការវិនិយោគរបស់ផ្នែកឯកជនលើវិស័យទូរគមនាគមន៍ និងការកើនឡើង នៃអ្នកប្រើប្រាស់ទូរស័ព្ទចល័តទីផ្សារទូរគមនាគមន៍នៅកម្ពុជាបានបោះជំហានចូលទៅក្នុងការប្រកួតប្រជែងគ្នាយ៉ាងស្វិតស្វាញរវាងប្រតិបត្តិករទូរគមនាគមន៍ទាំងអស់ ។

នាពេលថ្មីៗ រាជរដ្ឋាភិបាលសង្កេតឃើញថា ការតភ្ជាប់បណ្តាញគ្នាទៅវិញទៅមករវាងប្រតិបត្តិករទូរគមនាគមន៍មួយទៅប្រតិបត្តិករទូរគមនាគមន៍មួយទៀត ឬ ការហៅទូរស័ព្ទឆ្លងប្រព័ន្ធនៅជួបប្រទះការលំបាកស្មុគស្មាញបំផុត ដែលជាហេតុបង្កឱ្យមានផលវិបាកជាច្រើនចំពោះអ្នកប្រើប្រាស់ ។

កន្លងមកនេះ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍បានខិតខំប្រឹងប្រែង ព្យាយាមរិះរកគ្រប់មធ្យោបាយធ្វើអន្តរាគមន៍ដោះស្រាយបាតុភាពនេះបន្តបន្ទាប់រួចមកហើយ ប៉ុន្តែពុំទាន់បានទទួលលទ្ធផលផ្លែផ្កាល្អនៅឡើយ ។

ក្នុងមូលហេតុខាងលើនេះ ដើម្បីធានាឱ្យបានទូវការផ្តល់សេវាទូរគមនាគមន៍ប្រកបដោយគុណភាពល្អទាំងក្នុងប្រព័ន្ធក៏ដូចក្រៅប្រព័ន្ធ សំដៅចៀសវាងឱ្យបានទូវការថ្នាំងថ្នាក់ពីអ្នកប្រើប្រាស់ រាជរដ្ឋាភិបាលសម្រេចដាក់បទបញ្ជាដូចខាងក្រោម ៖

១ ) ប្រតិបត្តិករទូរគមនាគមន៍ ទាំងសហគ្រាសរដ្ឋនិងឯកជនត្រូវតែជានាលើការផ្តល់សេវាទូរគមនាគមន៍ប្រកបដោយគុណភាពល្អជូនអតិថិជនរបស់ខ្លួន ។

២ ) គ្រប់ប្រតិបត្តិករទូរគមនាគមន៍ត្រូវតែបញ្ឈប់ជាបន្ទាន់នូវការប្រកួតប្រជែងដណ្តើម អតិថិជនគ្នាតាមរយៈការរាំងខ្ទប់ការតភ្ជាប់បណ្តាញគ្នាទៅវិញទៅមក ។

៣ ) ការកំណត់ថ្លៃសេវារបស់គ្រប់ប្រតិបត្តិករទូរគមនាគមន៍ត្រូវផ្អែកលើមូលដ្ឋានថ្លៃដើមជាក់ស្តែងដែលទទួលស្គាល់ដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ។

៤ ) ការតភ្ជាប់បណ្តាញគ្នាទៅវិញទៅមកត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់តាមខ្លឹមសារនៃប្រកាសរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍លេខ២០៦ប.ទ. ចុះថ្ងៃទី០៥ខែតុលាឆ្នាំ២០០៩។

៥ ) ការប្រកួតប្រជែងគ្នាត្រូវប្រព្រឹត្តទៅក្នុងក្របខណ្ឌខ្លឹមសារនៃសារាចរអន្តរក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍លេខ ១២៧៧ ស.ហ.វ. - ប.ទ. ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០០៩ ។

៦ ) ការតភ្ជាប់បណ្តាញគ្នាទៅវិញទៅមករវាងប្រតិបត្តិករទូរគមនាគមន៍ទាំងអស់ត្រូវឆ្លងកាត់តាមមជ្ឈមណ្ឌលកណ្តាលនៃទូរគមនាគមន៍កម្ពុជា ។

ទូរគមនាគមន៍កម្ពុជាដែលជាអង្គភាពគ្រប់គ្រងចរន្តសេវាទូរគមនាគមន៍ឆ្លងកាត់ត្រូវផ្តល់ជូនក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ឱ្យបានទៀងទាត់និងជាប្រចាំនូវព័ត៌មានស្តីអំពីស្ថានភាពត្រាហ្វិក ( Traffic ) ដែលមានការបិទខ្ទប់ ។

បន្ថែមលើខ្លឹមសារនៃសារាចរអន្តរក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍លេខ ១២៧៧ ស.ហ.វ.-ប.ទ. ចុះថ្ងៃទី២៩ខែកញ្ញាឆ្នាំ២០០៩ ព្រមទាំងប្រកាសរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍លេខ ២០៦ ប.ទ. ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០០៩ រាជរដ្ឋាភិបាលនឹងចាត់វិធានការយ៉ាងម៉ឺងម៉ាត់ចំពោះប្រតិបត្តិករទូរគមនាគមន៍ណា ដែលពុំគោរពតាមបទបញ្ជានេះ ហើយនៅតែបន្តការបិទខ្ទប់ការតភ្ជាប់បណ្តាញគ្នាទៅវិញទៅមក ឬ ធ្វើសកម្មភាពប្រកួតប្រជែងគ្នាដោយពុំស្មោះត្រង់នាំឱ្យច្របូកច្របល់ស្ថានភាពទីផ្សារទូរគមនាគមន៍នៅកម្ពុជា ដូចខាងក្រោម ៖

ទី ១ ) សងការខាតបង់ជាប្រាក់ជូនភាគីជាដៃគូក្នុងកិច្ចសន្យា និង ផលប៉ះពាល់ចំពោះការបាត់បង់ចំណូលថវិការដ្ឋ,

ទី ២ ) ផ្តាច់បណ្តាញទាំងអស់ចេញពីមជ្ឈមណ្ឌលឆ្លងកាត់,

ទី ៣ ) ផ្អាកអាជ្ញាប័ណ្ណអាជីវកម្មបណ្តោះអាសន្ន ឬ ដកហូតអាជ្ញាប័ណ្ណអាជីវកម្មជាស្ថាពរ។

ទីស្ដីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួង ស្ថាប័ន ខេត្ត រាជធានី និង អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ព្រមទាំងប្រតិបត្តិករទូរគមនាគមន៍ទាំងអស់ ត្រូវអនុវត្តតាមបទបញ្ជានេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់សាលាខេត្ត រាជធានី
- ឯកសារ កាលប្បវត្តិ